សាលាដំបូងខេត្តបាត់ដំបង
បណ្ដឹងរដ្ឋប្បវេណី លេខ : ៩២
ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១
សាលក្រមលេខ: ២៤(ខ)
ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តាងនាមប្រជារាស្ត្រខ្មែរ
# តុលាការខេត្តបាត់ដំបង

នៅសាលាដំបូងខេត្តបាត់ដំបង បានបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាសាធារណៈលើសំណុំរឿងរដ្ឋប្បវេណីលេខ : ៩២ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១១ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១១ និងប្រកាសសាលក្រម នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ដែលមាន :

## ចៅក្រមជំនុំជម្រះ

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តបាត់ដំបង

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជីតុលាការរដ្ឋប្បវេណី

ដើមចោទ និងជាចុងបណ្ដឹងតវ៉ាឈ្មោះ [redacted] ធិចជូ ភេទស្រី អាយុ ៥២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ក្រុមទី០១ ភូមិថ្មគោល ឃុំតាពូង ស្រុកថ្មគោល ខេត្តបាត់ដំបង ។

ចុងចម្លើយនិងជាដើមបណ្ដឹងតបឈ្មោះ [redacted] បិន ភេទប្រុស អាយុ ៦៦ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ និងប្រពន្ធឈ្មោះ [redacted] នី អាយុ ៥៥ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅសព្វថ្ងៃក្រុមទី១១ ភូមិប្រគាប ឃុំរូងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ។

## អង្គហេតុ និង ចំណុចវិវាទ

### I-ការទាមទាររបស់ដើមចោទ និង ជាចុងបណ្ដឹងតវ៉ា :

១- សុំឱ្យចុងចម្លើយឈ្មោះ [redacted] បិន និងឈ្មោះ [redacted] នី ចេញពីដីដែលមានទំហំ ៦២០ ម៉ែត្រក្រឡា មានបណ្ដោយ ៥៧.៣ ម៉ែត្រ ទទឹងខាងត្បូង ១០.៤០ ម៉ែត្រ និងទទឹងខាងជើង ១១.២៥ ម៉ែត្រ ស្ថិតនៅភូមិប្រគាប ឃុំរូងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ។

២-ឱ្យចុងចម្លើយទាំងពីរនាក់សងប្រាក់ចំនួន ៩.៣៩៥ ដុល្លាអាមេរិក (ប្រាំបួនពាន់បីរយកៅសិបប្រាំដុល្លាអាមេរិក) ។

៣- ឱ្យចុងចម្លើយជាអ្នកបង់ប្រាក់ប្រដាប់ក្ដី ។

### II-ការទាមទាររបស់ចុងចម្លើយ និងជាដើមបណ្ដឹងតវ៉ា

១- សុំឱ្យបញ្ជាក់ពីនត្ថភាពនៃកាតព្វកិច្ចរបស់ឈ្មោះ [redacted] នី និងឈ្មោះ [redacted] បិន ក្នុងការសងប្រាក់ទៅឱ្យឈ្មោះ [redacted] ធិចជូ និងឈ្មោះ [redacted] សែ ចំនួន ៩.៣៩៥ ដុល្លាអាមេរិក (ប្រាំបួនពាន់បីរយកៅសិបប្រាំ

ដុល្លារអាមេរិក) ។

២-ចាត់ទុកជាមោឃៈនូវ :

ក/លិខិតលក់ផ្ដាច់អចលនវត្ថុ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៧ ដែលមានឈ្មោះ [redacted] បិន និងឈ្មោះ [redacted] នី ជាអ្នកលក់ ឈ្មោះ [redacted] ផិចជូ និងឈ្មោះ [redacted] សែ ជាអ្នកទិញដែលមានចំណារមេភូមិប្រគាបលេខ : ៧៨ ភ.ប.គ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ និងចំណារមេឃុំរូងជ្រៃលេខ : ២០៨ ឃ.រ.ជ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៧ ។

ខ/លិខិតបញ្ជាក់ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ ដែលមានដាក់ឈ្មោះ [redacted] នី និងឈ្មោះ [redacted] បិន ជាអ្នកទទួលទិញវិញ ឈ្មោះ [redacted] សែ និងឈ្មោះ [redacted] ផិចជូ ជាម្ចាស់ដី មានហត្ថលេខារបស់មេឃុំ ។

គ/កិច្ចសន្យាខ្ចីប្រាក់-ដាក់បញ្ចាំ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ ដែលមានដាក់ឈ្មោះ [redacted] នី និងឈ្មោះ [redacted] បិន ជាអ្នកខ្ចីប្រាក់ពីឈ្មោះ [redacted] សែ និងឈ្មោះ [redacted] ផិចជូ មានហត្ថលេខារបស់មេឃុំ ។

៣- បង្គាប់ឱ្យឈ្មោះ [redacted] ផិចជូ និងឈ្មោះ [redacted] សែ សងប្រាក់ចំនួន ៥.០០០ ដុល្លារអាមេរិក (ប្រាំពាន់ដុល្លារអាមេរិក) ឱ្យមកខ្ញុំបាទ-នាងខ្ញុំ ជាប្រាក់ដែលជំពាក់ក្នុងការទទួលបញ្ចាំដីនិងផ្ទះ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ ដែលមិនទាន់ឱ្យគ្រប់ចំនួន ។

៤- បង្គាប់ឱ្យឈ្មោះ [redacted] ផិចជូ និងឈ្មោះ [redacted] សែ ទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្ដី ។

III – **ការអះអាងរបស់ភាគី** :

ដើមចោទ និងជាចុងបណ្ដឹងតវ៉ាឈ្មោះ [redacted] ផិចជូ បានថ្លែងការណ៍ថា : នៅតែរក្សាការប្ដឹងទាមទារដីដែលចុងចម្លើយឈ្មោះ [redacted] បិន និងឈ្មោះ [redacted] នី លក់ឱ្យមកខ្លួនដែលស្ថិតនៅភូមិប្រគាប ឃុំរូងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ព្រមទាំងប្ដឹងសុំឱ្យចុងចម្លើយទាំងពីរនាក់សងប្រាក់ឱ្យខ្លួនចំនួន ៩.៣៩៥ ដុល្លារអាមេរិក (ប្រាំបួនពាន់បីរយកៅសិបប្រាំដុល្លារអាមេរិក) និងប្ដឹងទាមទារការខាតបង់ពេលវេលាចំនួន ១០.០០០.០០០ រៀល (ដប់លានរៀល) ដោយសំអាងលើលិខិតបីសន្លឹក លិខិតលក់ផ្ដាច់អចលនវត្ថុ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ០០៧ ០១សន្លឹក ,កិច្ចសន្យាខ្ចីប្រាក់-បញ្ចាំទ្រព្យ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ ០១សន្លឹក និងលិខិតបញ្ជាក់ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ ០១សន្លឹក បើចុងចម្លើយសុខចិត្តប្រគល់ដី និងផ្ទះឱ្យខ្លួន១មិនទាមទារប្រាក់បំណុលទៀតទេ ។

- ចុងចម្លើយនិងជាដើមបណ្ដឹងតបឈ្មោះ [redacted] បិន និងឈ្មោះ [redacted] នី បានថ្លែងការណ៍ថា ទទួលស្គាល់តែលិខិតខ្ចីចងការប្រាក់ដែលបានផ្ដិតមេដៃ ក្រៅពីនោះលិខិតខ្ចីប្រាក់បញ្ចាំទ្រព្យ និងលិខិតបញ្ជាក់ សុំទិញផ្ទះវិញ ខ្លួនសុំបដិសេធចោល ឯប្រាក់បំណុលទទួលស្គាល់ចំនួន ៥.០០០ ដុល្លារអាមេរិក សុំសងប្រាក់ និងរស់នៅលើដីនោះវិញ ។

- លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ និងជាដើមបណ្តឹងតប បានថ្លែងការណ៍ថា : សុំឱ្យតុលាការសម្រេចច្រានចោលការទាមទាររបស់ដើមចោទទាំងបីចំណុច និងសុំឱ្យតុលាការបញ្ជាក់ពីនត្ថភាពកាតព្វកិច្ចរបស់ចុងចម្លើយក្នុងការសងប្រាក់ទៅដើមចោទចំនួន ៩.៣៩៥ ដុល្លារអាមេរិក ចំណុចទីបី សុំឱ្យតុលាការចេញលិខិតបញ្ជាក់មោឃភាពនូវឯកសារនៃពាក្យបណ្តឹងតបទាំងបី ឱ្យដើមចោទបង់ប្រាក់ចំនួន ៥.០០០ ដុល្លារអាមេរិក ជាប្រាក់ដែលដាក់បញ្ចាំដី និងផ្ទះ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ ដែលដើមចោទឱ្យមិនទាន់គ្រប់ចំនួន ព្រមទាំងឱ្យដើមចោទជាអ្នកបង់ប្រាក់ប្រដាប់ក្តី មូលហេតុទាមទារឱ្យបញ្ជាក់នត្ថភាព ដោយហេតុថានៅឆ្នាំ១៩៩៩ ចុងចម្លើយបានខ្ចីប្រាក់ពីដើមចោទចំនួន ១៤.៣៩៥ ដុល្លារអាមេរិក ហើយប្រាក់បំណុលនោះចុងចម្លើយបានសងជាបន្តបន្ទាប់ ហើយប្រាក់បំណុលនោះជំពាក់ពីមុន រហូតមកដល់ដើមបណ្តឹងប្តឹងមានរយៈពេលលើសពី ៥ឆ្នាំហើយ ដល់ឆ្នាំ២០០៧ ចុងចម្លើយបានដាក់ផ្ទះបញ្ចាំឱ្យដើមចោទចំនួន ១០.០០០ ដុល្លារអាមេរិក តែចុងចម្លើយឱ្យតែចំនួន ៥.០០០ ដុល្លារអាមេរិក ប៉ុណ្ណោះ ឯ ៥.០០០ ដុល្លារអាមេរិកទៀតដើមចោទយកកាត់កងបំណុលពីមុនមានចំនួន ១៤.៣៩៥ ដុល្លារអាមេរិក នៅសល់ចំនួន ៩.៣៩៥ ដុល្លារអាមេរិក ទើបទាមទារឱ្យដើមចោទបង់ឱ្យចុងចម្លើយ ៥.០០០ ដុល្លារអាមេរិក ទៀតបង្រប់ប្រាក់ខ្ចីចងការ ហើយការទាមទារនត្ថភាពទាមទារលើកិច្ចសន្យាខ្ចីចងការប្រាក់ដែលមានរយៈពេលហួសច្បាប់កំណត់ ចំពោះការប្តឹងទាមទារសំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលា ត្រូវជាលាយលក្ខអក្សរដាក់ជូនតុលាការដើម្បីឱ្យចុងចម្លើយដឹងជាមុន ។

- ឈ្មោះ [redacted] សឿម ជាសាក្សី និងជាមេឃុំរូងជ្រៃ បានថ្លែងការណ៍ថា : ចំពោះលិខិតលក់ផ្តាច់ គឺលោក [redacted] បិន បានឯកភាពព្រមព្រៀងគ្នានៅមុខមេឃុំរូងជ្រៃ ហើយលិខិតលក់ផ្តាច់ខ្លួនជាអ្នកសរសេរ មានភាគីផ្តិតមេដៃដោយព្រមព្រៀងទាំងអស់គ្នា តម្លៃ ១០.០០០ ដុល្លារអាមេរិក ចំពោះលិខិតសុំទិញដី និងផ្ទះ គឺជាការព្រមព្រៀងរបស់ឈ្មោះ [redacted] បិន និងឈ្មោះ [redacted] សែ គឺលោក [redacted] បិន ខ្ចាចលោក [redacted] សែ មិនលក់ឱ្យវិញក្នុងរយៈពេលបីឆ្នាំ ឯកិច្ចសន្យាជំពាក់ប្រាក់ ពុំមានដាក់ថ្ងៃ-ខែ ព្រោះទុកពេលឱ្យឈ្មោះ [redacted] បិន សងប្រាក់ពេលដែលគាត់រកបាន ហើយលិខិតទាំងអស់នោះ ឈ្មោះ [redacted] បិន ពឹងឱ្យខ្លួនជាអ្នកសរសេរឱ្យទាំងអស់ ហើយលិខិតទាំងនោះខ្លួនចុះហត្ថលេខា និងប្រថាប់ត្រាឱ្យទៀត ។

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូរភាគី

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់សាក្សី

**IV- ចំណុចវិវាទ :** -លិខិតលក់ផ្តាច់អចលនវត្ថុ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧

-កិច្ចសន្យាខ្ចីចងការប្រាក់-បញ្ចាំទ្រព្យ ចុះថ្ងៃទី៣០-៥-២០០៧

- លិខិតបញ្ជាក់ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧

**ចំណុចគ្មានវិវាទ :** គ្មាន ។

Scanned with CamScanner

## សំអាងហេតុ

- ពាក្យបណ្ដឹង ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១ របស់ដើមចោទឈ្មោះ [redacted] ផិចជូ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ ។

- ពាក្យបណ្ដឹងតប ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ប៊ិន និងឈ្មោះ [redacted] ធី ធ្វើឡើងត្រឹមត្រូវតាមទម្រង់ តែផ្ទុយនឹងគតិច្បាប់ ។

- ចុងចម្លើយ និងជាដើមបណ្ដឹងតបឈ្មោះ [redacted] ប៊ិន និងឈ្មោះ [redacted] ធី ពិតជាបានទំនាក់ទំនងខ្ចីចងការប្រាក់ពីឈ្មោះ [redacted] ផិចជូ និងបានលក់អចលនវត្ថុ មានលិខិតលក់ ផ្ដាច់អចលនវត្ថុ .កិច្ចសន្យាខ្ចីប្រាក់ និងលិខិតបញ្ជាក់ជាភស្តុតាង ។

- ដើមចោទប្ដឹងសុំឱ្យចុងចម្លើយ និងជាដើមបណ្ដឹងតបទាំងពីរនាក់ប្ដីប្រពន្ធប្រគល់ដី និងផ្ទះដែលបានលក់ឱ្យខ្លួន តាមលិខិតលក់ផ្ដាច់អចលនវត្ថុ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ ជាភស្តុតាង និងសុំឱ្យចុងចម្លើយទាំងពីរនាក់សងប្រាក់ជំពាក់ដែល នៅសល់គ្រប់ចំនួន ដូចមានកិច្ចសន្យាខ្ចីចងការប្រាក់-បញ្ចាំទ្រព្យ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ ជាភស្តុតាងស្រាប់ មានលក្ខណៈត្រឹមត្រូវអាចឱ្យតុលាការពិចារណាបាន ។

- ចុងចម្លើយ និងជាដើមបណ្ដឹងតបទាំងពីរនាក់ នៅក្នុងនីតិវិធីត្រៀមទាញហេតុផល បដិសេធមិនព្រមទទួលស្គាល់ថាបានផ្ដិតមេដៃលើលិខិតទាំងបីសន្លឹកនោះទេ ដោយសំអាងថាដើមចោទបានយកក្រដាសទទេពុំមានសរសេរអក្សរជាលាយលក្ខអក្សរឱ្យខ្លួនផ្ដិត ស្នើសុំឱ្យតុលាការធ្វើកោសល្យវិច័យស្នាមមេដៃលើលិខិតទាំងបីនោះឱ្យបានច្បាស់លាស់ មានលក្ខណៈត្រឹម ត្រូវអាចឱ្យតុលាការបាន ។

- តាមពាក្យស្នើសុំឱ្យធ្វើកោសល្យវិច័យ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១ របស់លោក [redacted] ជាមេធាវី តំណាងដោយអាណត្តិឱ្យចុងចម្លើយ និងតាមលទ្ធផលកោសល្យវិច័យ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ របស់នាយកដ្ឋាននគរបាលបច្ចេកទេស និងវិទ្យាសាស្ត្រ បានធ្វើកោសល្យវិច័យលើលិខិតលក់ផ្ដាច់អចលនវត្ថុ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០០៧ .កិច្ចសន្យាខ្ចីចងការប្រាក់-បញ្ចាំទ្រព្យ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ .លិខិតបញ្ជាក់ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ និងលិខិតជួលដី និងផ្ទះ ពុំមានចុះថ្ងៃ-ខែ-ឆ្នាំ ក្រោយពីធ្វើការប្រៀបធៀបគ្នារវាងស្នាមមេដៃដែលមាននៅលើលិខិតទាំងបួនសន្លឹកនិងគំរូស្នាមមេដៃស្ដាំរបស់ឈ្មោះ [redacted] ធី និងឈ្មោះ [redacted] ប៊ិន ពិតជា ស្នាមក្រយៅដៃដូចគ្នារបស់មនុស្សតែម្នាក់ បញ្ជាក់ថាឈ្មោះ [redacted] ធី និងឈ្មោះ [redacted] ប៊ិន ពិតជាបានផ្ដិតមេដៃលើលិខិតទាំងនោះមែន ។

- តាមលិខិតលក់ផ្ដាច់ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ .កិច្ចសន្យាខ្ចីប្រាក់-បញ្ចាំទ្រព្យ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ និងលិខិតបញ្ជាក់ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ មានស្នាមមេដៃឈ្មោះ [redacted] ធី [redacted] ប៊ិន ជាកូនបំណុល និងមានឈ្មោះ [redacted] ផិចជូ និងឈ្មោះ [redacted] សែ ជាម្ចាស់បំណុល និងបញ្ជាក់ថាកូនបំណុលបានលក់ផ្ដាច់អចលនវត្ថុមានផ្ទះ និងដីមួយកន្លែង ទំហំ ៦២០ ម៉ែត្រការេ ស្ថិតនៅភូមិប្រគាប ឃុំរងជ្រៃ .ស្រុកថ្មគោល ខេត្តបាត់ដំបង ទៅឱ្យម្ចាស់បំណុលក្នុងតម្លៃ ១០.០០០ ដុល្លារអាមេរិក កូនបំណុលខ្ចាច់គ្រែងម្ចាស់

Scanned with CamScanner

បំណុលមិនព្រមលក់ឱ្យខ្លួនវិញ ម្ចាស់បំណុលក៏សុខចិត្តធ្វើលិខិតបញ្ជាក់ឱ្យកូនបំណុលព្រមលក់ឱ្យកូនបំណុលវិញ ក្នុងតម្លៃ ១៣.០០០ ដុល្លាអាមេរិក ក្នុងរយៈពេលបីឆ្នាំ ។

- ចុងចម្លើយនៅពេលទាញហេតុផលផ្ទាល់មាត់ នៅតែបដិសេធលើលិខិតទាំងបីនោះដដែល តែទទួលស្គាល់ថាបានខ្ចីប្រាក់ដើមចោទចំនួន ៥.០០០ ដុល្លាអាមេរិក សុំសងប្រាក់គ្រប់ចំនួន តែសុំគ្រប់គ្រងដី និងផ្ទះ តែដើមចោទមិនព្រម ចំណុចនេះមិនអាចឱ្យតុលាការពិចារណាបានទេ ។

- មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ សុំឱ្យតុលាការបញ្ជាក់ពីនត្ថភាពនៃកាតព្វកិច្ចរបស់ឈ្មោះ [redacted] នី និងឈ្មោះ [redacted] ប៊ិន ក្នុងការសងប្រាក់ឱ្យទៅដើមចោទ និងសុំឱ្យតុលាការមោឃភាពលើលិខិតទាំងបីនោះ មានលក្ខណៈមិនច្បាស់លាស់មិនអាចឱ្យតុលាការពិចារណាបានឡើយ ដោយគ្មានភស្តុតាងអ្វីបញ្ជាក់ ហើយម្យ៉ាងទៀតលទ្ធផលកោសល្យវិច័យបានបញ្ជាក់ឃើញស្រាប់ហើយ ។

- ឈ្មោះ [redacted] សឿម ជាសាក្សី និងជាមេឃុំរូងជ្រៃ បានអះអាងថា លិខិតទាំងបីសន្លឹកដែលមានស្នាមមេដៃរបស់ឈ្មោះ [redacted] ប៊ិន ប្រពន្ធឈ្មោះ [redacted] នី និងឈ្មោះ [redacted] សែ និងប្រពន្ធឈ្មោះ [redacted] ធិចជូ ពិតជាស្នាមមេដៃពិតប្រាកដ មិនមែនក្លែងបន្លំទេ ព្រោះឈ្មោះ [redacted] ប៊ិន បានពឹងពាក់ឱ្យខ្លួន (ជាអាជ្ញាធរ)សរសេរលិខិតលក់ផ្តាច់អចលនវត្ថុ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ ហើយធ្វើនៅចំពោះមុខខ្លួន (ជាមេឃុំ) ថែមទាំងឱ្យខ្លួនធ្វើលិខិតបញ្ជាក់ថា ទិញយកវិញពីឈ្មោះ [redacted] សែ និងឈ្មោះ [redacted] ធិចជូ ខ្លាចគេមិនលក់ឱ្យវិញ និងលិខិតខ្ចីចងការប្រាក់ចំនួន ៩.៣៩៥ ដុល្លាអាមេរិក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ ការធ្វើនេះគឺឈ្មោះ [redacted] ប៊ិន និងឈ្មោះ [redacted] នី មករកសុំដោយស្ម័គ្រចិត្ត មិនមានអ្នកណាបង្ខំឡើយ ចំណែកការជូលផ្ទះនោះទៅវិញ ជារឿងឈ្មោះ [redacted] សែ និងឈ្មោះ [redacted] ប៊ិន និងឈ្មោះ [redacted] ខ្លួនពុំដឹងទេ ។

- ចុងចម្លើយទទួលស្គាល់ថាពិតជាបានជំពាក់ប្រាក់ដើមចោទចំនួន ៥.០០០ ដុល្លាអាមេរិក ដូច្នេះការស្នើសុំរបស់មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយសុំឱ្យតុលាការបញ្ជាក់ពីនត្ថភាព មិនមានលក្ខណៈច្បាស់លាស់ គឺគ្មាននត្ថភាពតែម្តង ហើយការស្នើសុំនោះមិនអាចឱ្យតុលាការពិចារណាបានឡើយ ដោយគ្មានភស្តុតាង ។

- លិខិតលក់ផ្តាច់ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ កិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ និងលិខិតបញ្ជាក់ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ នេះ ជាលិខិតធ្វើឡើងត្រឹមត្រូវ គ្មានភាគីណាបង្ខំឡើយ នៅចំពោះមុខអាជ្ញាធរទៀត អាចឱ្យតុលាការយកជាការបាន ។

- ការប្តឹងទាមទារឱ្យចុងចម្លើយទាំងពីរនាក់ប្រគល់ដីនិងផ្ទះ និងឱ្យសងប្រាក់ចំនួន ៩.៣៩៥ ដុល្លាអាមេរិក មានលក្ខណៈត្រឹមត្រូវ អាចឱ្យតុលាការពិចារណាបាន តែការប្តឹងសុំសំណងជម្ងឺចិត្ត តុលាការមិនអាចពិចារណាបានទេ ព្រោះដើមចោទក៏មិនទាមទារដាច់ខាតដែរ ។

- គប្បីសម្រេចដល់ប្រាក់ប្រដាប់ក្តីទៅតាមច្បាប់ ។

## សេចក្តីសម្រេចបញ្ចប់

១- ក/ទទួលពាក្យបណ្តឹង ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១១ របស់ដើមចោទឈ្មោះ [redacted] ជិចជូ ថ្ងៃឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ។

ខ/ទទួលពាក្យបណ្តឹងតប ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] នី និង ឈ្មោះ [redacted] បិន ថ្ងៃឡើងត្រឹមត្រូវតាមទម្រង់ តែបដិសេធចោល ដោយផ្ទុយនឹងអង្គច្បាប់ ។

២- ទទួលស្គាល់លិខិតលក់ផ្តាច់អចលនវត្ថុ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ . កិច្ចសន្យាខ្ចីប្រាក់-បញ្ចាំទ្រព្យ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ និងលិខិតបញ្ជាក់ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] នី និងឈ្មោះ [redacted] បិន ប្រគល់ដី និងផ្ទះ ដែលមានទំហំ ៦២០ ម៉ែត្រក្រឡា ស្ថិតនៅភូមិស្វាយប្រតាប ឃុំរូងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ឱ្យទៅឈ្មោះ [redacted] ជិចជូ ជាដើមបណ្តឹង ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

៤- បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] នី និងឈ្មោះ [redacted] បិន រួមគ្នាសងប្រាក់ចំនួន ៩.៣៩៥ ដុល្លាអាមេរិក (ប្រាំបួនពាន់បីរយកៅសិបប្រាំដុល្លាអាមេរិក) ទៅដើមចោទឈ្មោះ [redacted] ជិចជូ ចាប់ពីពេលសាលក្រមចូលជាស្ថាពរ ការទាមទារលើសពីនេះបដិសេធចោល ។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

ចៅក្រមជំនុំជម្រះ
ហត្ថលេខា និង ឈ្មោះ
[redacted]

................................................................................................................

បានថតចំលងត្រឹមត្រូវតាមសាលក្រមដើម
បាត់ដំបង ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១
ក្រឡាបញ្ជី
[redacted]

បានឃើញ
បាត់ដំបង ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១
ចៅក្រមជំនុំជម្រះ
[redacted]

[illegible] ១២៤៧
ថ្ងៃទី១៣ ខែ[illegible] ឆ្នាំ២០១១
[illegible]
51 ៥១ [redacted]